# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 912

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន(ផ្នែកវារីវប្បកម្ម)

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/18 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/25 |
| ៣. ចំណាយគម្រោងសរុប | $37,555,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| RESPONSIBLE UNIT | Fisheries Administration |
| អង្គភាពទទួលខុសត្រូវ | រដ្ឋបាលជលផល |
| ៥. ស្ថានភាពគម្រោង | គម្រោងដែលបានបញ្ចប់ |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ជំនួយឥតសំណង |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

សម្រាប់កម្រិតថ្នាក់ជាតិ យុទ្ធសាស្ត្រចតុកោនបានដាក់នូវវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់ការរីកចំរើន ភាពមានការងារធ្វើ សមភាព និងប្រសិទ្ធភាពជាមួយនឹងការសង្កត់ធ្ងន់លើការលើកកម្ពស់វិស័យកសិកម្មនៃភាពសំបូរបែបនៃអាហារ។ វិស័យអទិភាពនៃយុទ្ធសាស្ត្រចតុកោណ ត្រូវបានធ្វើការពន្យល់បង្ហាញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP)។ យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានទទួលស្គាល់ពីសារប្រយោជន៍នៃវិស័យជលផល ដែនកំណត់នៃផលចាប់ធម្មជាតិ និងភាពចាំបាច់ដែលត្រូវផ្តោតទៅលើការអភិវឌ្ឍវិស័យវារីវប្បកម្ម និងខ្សែច្រវ៉ាក់តម្លៃដើម្បីបង្កើនភាពរីកចំរើន។ ដៃគូអភិវឌ្ឍបានធ្វើការចូលរួមយ៉ាងសកម្មក្នុងការបង្កើត NSDP តាមរយៈការពិភាក្សាជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងពាក់ព័ន្ធ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

ព្រៃវែង, បាត់ដំបង, ពោធិ៍សាត់, កំពង់ធំ, កណ្ដាល, សៀមរាប, បន្ទាយមានជ័យ, តាកែវ, កំពង់ចាម, កំពង់ឆ្នាំង,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គោលបំណងរួមនៃកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ននៃវារីវប្បកម្មត្រូវបានអនុលោមទៅតាមផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ដើម្បីចូលរួមក្នុងសន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងបង្រឹងជីវភាពរស់នៅរបស់ប្រជាជន និងការរីកចំរើនជាត់។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

:ដើម្បីសម្រេចបាននូវសូចនាករដែលបានចែងនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីវប្បកម្មជាតិសម្រាប់កម្ពុជា។ គម្រោងCaPFish ត្រូវបានណែនាំនិងផ្តល់មូលនិធិដោយសហភាពអឺរ៉ុប។គម្រោងនេះមាន ពីរសមាសភាព:

១) សមាសភាគទី៖ សកម្មភាព

១.១ ការគាំទ្រដល់ការបង្កើនផលិតកម្មកូនត្រីរបស់ជាតិរួមទាំងប្រភេទសត្វដែលអាចធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ - ពូជ

១.២ វាយតម្លៃភាពងាយរងគ្រោះទៅនឹងការប្រែប្រួលលអាកាសធាតុនិងផលប៉ះពាល់ជាសក្តានុពលលើវារីវប្បកម្មនិងបង្កើតប្រព័ន្ធព័ត៌មានស្តីពីហានិភ័យពាក់ព័ន្ធនឹងលទ្ធភាពទទួលបានទឹកនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ - ទឹក / ការផ្លាស់ប្តូរអាកាសធាតុ

១.៣ ការគាំទ្រដល់ការពង្រីកនៃការប្រើប្រាស់ចំណីគ្រាប់, ការត្រួតពិនិត្យគុណភាព, និងការផលិតចំណីរបស់ជាតិ - ចំណី

១.៤ លើកកម្ពស់កំរិតចំណេះដឹងនិងជំនាញរបស់មន្ត្រីក្នុងវិស័យសាធារណៈនិងឯកជន - ចំណេះដឹង

១.៥ ការដឹកនាំ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាននៃផលិតកម្មវារីវប្បកម្មទៅលើបរិស្ថាន - បរិស្ថាន

១.៦ ការគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារនៃផលិតកម្មវារីវប្បកម្ម - គុណភាព / សុវត្ថិភាព

១.៧ ក្របខ័ណ្ឌសម្រាប់បង្កើតសេវាហិរញ្ញវត្ថុដែលអាចទទួលយកបានសម្រាប់ការអភិវឌ្ឍវារីវប្បកម្ម - ហិរញ្ញវត្ថុ

១.៨ ពង្រឹងសមត្ថភាពអភិបាលកិច្ចនិងការចូលរួមរបស់ស្ត្រីនិងការគាំទ្រដល់កំណើនប្រាក់ចំណូលនៃគ្រួសារក្រីក្រនៅជនបទ - អភិបាលកិច្ច

១.៩ ការកែលម្អស្ថានភាពអាហារូបត្ថម្ភរបស់គ្រួសារ - អាហារូបត្ថម្ភ

២) សមាសភាគទី៖ ជំនួយបច្ចេកទេសនិងការគ្រប់គ្រងកម្មវិធី

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

សកម្មភាពនេះជាផ្នែកមួយនៃការទទួលខុសត្រូវរបស់សហភាពអឺរ៉ុបក្នុងការដោះស្រាយបញ្ហាក្នុងវិស័យជលផល ដើម្បីបង្កើនសន្តិសុខស្បៀង កែលម្អអាហារូបត្ថម្ភ និងជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច ដែលបង្កើតឡើង ២សមាសភាគ គឺវារីវប្បកម្ម និងផលចាប់ជលផល។ សភាសភាគវារីវប្បកម្មនេះស្នើសុំការរៀបចំជាប្រព័ន្ធ និងការចូលរួមយ៉ាងទូលាយដើម្បីគាំទ្រវិស័យនេះស្របទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីវប្បកម្មជាតិ និងការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌផែនការវិស័យជលផល។ វានឹងគាំទ្រការអភិវឌ្ឍ និងបង្កើនកម្រិតជោគជ័យនៃភាពទន់ខ្សោយនៃប្រព័ន្ធវារីវប្បកម្ម ដូចជាការអភិវឌ្ឍ និងការផ្សព្វផ្សាយនៃនិន្នភាព និងប្រសិទ្ធិភាពនៃការអនុវត្តក្នុងការរីកចម្រើននៃវិស័យពាណិជ្ជកម្ម។ សកម្មភាពនេះនឹងរួមចំណែកដល់ការពង្រឹងបន្ថែមនូវសមត្ថភាព និងប្រព័ន្ធជាតិ ស្របតាមគោលការណ៍នៃសេចក្តីថ្លែងការណ៍ប៉ារីសស្តីពីការបង្កើនប្រសិទ្ធភាពជំនួយ។ សកម្មភាពនេះនឹងរួមចំណែកដើម្បីសម្រេចលទ្ធផល ១ (ធ្វើអោយប្រសើរនៃលំហរបរិស្ថានមុខជំនួញ) និង ២ (ពង្រឹងខ្សែរចង្វាក់ផលិតកម្ម) នៃកម្មវិធីសហប្រតិបត្តិការរបស់សភាពអឺរ៉ុប និងកម្ពុជា ឆ្នាំ២០១៤ ដល់២០២០ (វារីវប្បកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ)។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

**អ្នកទទួលផល (គ្រួសារតាមជនបទ វារីវប្បករខ្នាតតូច និងពាណិជ្ជកម្ម ស្ថានីយ៍បង្កាត់ក្បាស់រដ្ឋនិងឯកជន មជ្ឈមណ្ឌលស្រាវជ្រាវជាតិ និងមន្ត្រីរដ្ឋបាលជលផល)**

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **ត្រូវបានបញ្ចប់**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**មិនមានផលប៉ះពាល់អវិជ្ជមានទៅដល់សង្គម និងបរិស្ថាននោះទេ ប៉ុន្តែគម្រោងនេះនឹងជួយបង្កើនប្រាក់ចំណូលដល់គ្រួសារក្រីក្រតាមតំបន់ជនបទ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

ក្រុមការងារជាតិនឹងត្រូវបានគាំទ្រ និងពង្រឹងសមត្ថភាពដោយជំនួយការបច្ចេកទេសអន្តរជាតិរយៈពេលវែង។
លើសពីនេះទៀតក្រុមអ្នកជំនាញពិសេសអាចត្រូវបានកៀងគរសម្រាប់ធាតុចូលជាក់លាក់ដូចជាការសរសេរ ToRs។
វត្តមានរបស់អ្នកជំនាញការអន្តរជាតិនេះនឹងថយចុះនៅពេលដែលគម្រោងត្រូវបង្កើនការទទួលខុសត្រូវលើក្រុមការងារថ្នាក់ជាតិ។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

សម្រាប់កម្រិតថ្នាក់ជាតិ យុទ្ធសាស្ត្រចតុកោនបានដាក់នូវវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់ការរីកចំរើន ភាពមានការងារធ្វើ សមភាព និងប្រសិទ្ធភាពជាមួយនឹងការសង្កត់ធ្ងន់លើការលើកកម្ពស់វិស័យកសិកម្មនៃភាពសំបូរបែបនៃអាហារ។
វិស័យអទិភាពនៃយុទ្ធសាស្ត្រចតុកោណត្រូវបានធ្វើការពន្យល់បង្ហាញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ យុទ្ធសាស្ត្រចតុកោណ

**២៣.** [illegible] បណ្តាល
ឲ្យ [illegible] អភិវឌ្ឍវិស័យវារីវប្បកម្ម និងខ្សែច្រវ៉ាក់តម្លៃដើម្បីបង្កើនភាពរីកចំរើន។

កំពុងដំណើរការ

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

AFD នឹងធ្វើការគ្រប់គ្រងគម្រោងក្នុងកិច្ចសហប្រតិបត្តការជាមួយអ្នកទទួលផល (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/រដ្ឋបាលជលផល)។ AFD នឹងធ្វើការគ្រប់គ្រងលើការងារអនុវត្តថវិការ រួមមានត្រួតពិនិត្យ និងយល់ព្រមលើផែនការការងារដែលត្រូវបានស្នើដោយអ្នកទទួលផល ត្រួតពិនិត្យនិងការប្រតិបត្តផែនការការងារនិងលទ្ធកម្ម និងកិច្ចសន្យា ទទួលយកនូវលទ្ធផល ធ្វើការទូទាត់និងការទូទាត់ហួសកំណត់។ AFD ក៏ត្រូវធ្វើការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសទៅអោយអ្នកទទួលផល ដឹកនាំនិងត្រួតពិនិត្យការអនុវត្តគម្រោង សម្របសម្រួលផ្នែកវារីវប្បកម្ម ចូលរួមការអនុវត្តគោលនយោបាយ និងធ្វើរបាយការណ៍ទៅឲ្យអ៊ឺយូ។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 3,829.5 | 28.6 | 394.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 46.0 | 25.7 | 103.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 3,783.5 | 2.9 | 290.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 8,936.5 | 3,282.4 | 13,002.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 1,363.6 | 283.4 | 4,125.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សេវាទីប្រឹក្សា | 7,257.9 | 2,693.7 | 5,864.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 190.0 | 181.6 | 1,651.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្ដុះបណ្ដាល | 125.0 | 123.7 | 1,060.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 300.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 12,766.0 | 3,311.0 | 13,396.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 25.7 | 103.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 25.7 | 103.6 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 12,766.0 | 3,285.3 | 13,292.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| European Commission | 12,766.0 | 3,285.3 | 13,292.6 | 0.0 | 0.0 | 0.0 | 0.0 | |
| Other | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 12,766.0 | 3,311.0 | 13,396.2 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: